គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

ខុមហ្វ្រែល COMFREL

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**

**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ២០/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត កែប

*ភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨៨នាក់ មកពីគ្រប់ស្រុកនៅក្នុងខេត្តកែបនិងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ៥៤%បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកែប ដែលត្រូវបានធ្វើឡើងកាលពីចុងខែសីហា ឆ្នាំ ២០០៩។

អភិបាលរងខេត្តកែប ឯកឧត្តម **កែវ សត្ថា** មានប្រសាសន៍ថា រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ដែលគ្របដណ្តប់ស្ទើរគ្រប់វិស័យ ហើយសិក្ខាសាលានេះគឺដើម្បីផ្តល់ឱកាសដល់ម្ចាស់ឆ្នោតបង្ហាញពីតម្រូវការរបស់ខ្លួនដល់មន្ត្រីជាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សាខេត្តកែប ឯកឧត្តម **មុត មន** ក៏បានមានប្រសាសន៍ថា គំនិតសំខាន់ៗដែលជាការប្រមូលផ្តុំរបស់ប្រជាពលរដ្ឋទាំង២ស្រុក ដែលបានកំនត់នូវវិស័យអាទិភាពទាំង ១០ ដើម្បីជំរុញអភិវឌ្ឍន៍ខេត្តកែប។ ឯកឧត្តម ” *សុំទទួលយកនូវចំនុចទាំងនេះសំរាប់ក្រុមប្រឹក្សាធ្វើការពិចារណា ហើយនឹងដាក់ជូនទៅគណ:អភិបាលខេត្តនៅពេលប្រជុំ។*

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តកែបដូចខាងក្រោមៈ

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកែបរួមមានៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងខេត្ត កែប** |
|---|
| ១) សុំអាជ្ញាធរខណ្ឌរដ្ឋបាលជលផល បង្ក្រាបបទល្មើសនេសាទខុសច្បាប់ នៅដែននេសាទសហគមន៍ (នៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ដូចជាទូកអូសឆក់ មូងកែវ ក្រឡាល្អិត) និងដែននេសាទសមុទ្រខេត្តកែប និងបទល្មើសនេសាទអន្តរជាតិ អោយបាន ១០០% និងឱ្យបាននៅក្នុងឆ្នាំ២០០៩។ |

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើត ស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ២) សុំមន្ទីរកសិកម្មខេត្ត ផ្តល់ការបណ្តុះបណ្តាលធនធានមនុស្ស លើបច្ចេកទេសធ្វើជីកំប៉ុស ដាំដំណាំស្រូវ ដំណាំរួមផ្សំ និងការចិញ្ចឹម សត្វ (គោ ជ្រូក មាន់ ទា...) ដល់ប្រជាពលរដ្ឋ ទូទាំងខេត្តកែប ឱ្យបានជារៀងរាល់ឆ្នាំ ដោយចាប់ផ្តើមនៅដើម ឆ្នាំ២០១០។ |
| ៣) សុំមន្ទីរកសិកម្មខេត្ត ផ្តល់ពូជស្រូវដែលមានផ្លែល្អ និងពូជសត្វ (គោ ជ្រូក មាន់ ទា...) ដល់ប្រជាពលរដ្ឋដែលធ្វើកសិកម្ម នៅទូទាំងខេត្តកែប ឱ្យបាននៅដើមឆ្នាំ២០១០។ |
| ៤) សុំឱ្យរដ្ឋាភិបាលផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី តាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ដល់ប្រជាពលរដ្ឋ ដោយមិនគិតថ្លៃ នៅទូទាំងខេត្តកែប ឱ្យបាន ១០០% នៅក្នុងឆ្នាំ២០១០។ |
| ៥) សុំឱ្យមានមណ្ឌលសុខភាព នៅសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ចំនួន ១ កន្លែង និង [បុគ្គលិក] ប្រកបដោយជំនាញ វិជ្ជាជីវៈគ្រប់គ្រាន់ និងក្រមសីលធម៌ និងកុំឱ្យមានការបង់ប្រាក់ថ្លៃសេវាព្យាបាល ឱ្យបាននៅចុងឆ្នាំ២០១០។ |
| ៦) សុំបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ (ជួសជុលម៉ូតូ កង់ ឡាន និងម៉ាស៊ីនទូក) ១ កន្លែងនៅក្នុងភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ឱ្យហើយនៅឆ្នាំ២០១២។ |
| ៧) សុំឱ្យអាជ្ញាធរមូលដ្ឋាន និងកំលាំងមានសមត្ថកិច្ច លុបបំបាត់ឱ្យបាន [១០០%] នូវបញ្ហាចំនួន ៣ ដូចជាក្មេងទំនើង គ្រឿងញៀន ល្បែងស៊ីសង នៅទូទាំងខេត្តកែប ឱ្យបាននៅឆ្នាំ២០១០។ |
| ៨) សុំឱ្យអាជ្ញាធរខេត្ត ជួយជំរុញក្រុង [ស្រង់ស្ថិតិក្មេងតាមផ្ទះ] ដែលគ្រប់អាយុចូលរៀន និងក្មេងកំព្រា ឱ្យបានចូលរៀនគ្រប់ៗគ្នា [ អោយបាន ១០០% ] នៅទូទាំងខេត្តកែប ចាប់ពី ឆ្នាំ២០១០ នេះតទៅ។ |
| ៩) សុំអោយអាជ្ញាធរមូលដ្ឋានជួយសហការបង្កើតសហគមន៍ទេសចរណ៍ព្រៃកោងកាង មួយនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ចាប់ពីខែ ១០ ឆ្នាំ២០០៩ បញ្ចប់នៅក្នុងឆ្នាំ២០១០។ |
| ១០) ស្តារប្រឡាយទឹក និងធ្វើទ្វារទឹក នៅក្នុងភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ប្រវែង ៥០០ម ឱ្យបាននៅ ដើមឆ្នាំ២០១០ និងផ្លូវលំ ២ខ្សែ គឺខ្សែទី១ ពីចំណុចផ្លូវតាពីង ដល់ស្រែយុល (ភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ)ខ្សែទី២ ពីផ្លូវជាតិលេខ៣៣ ដល់មាត់ព្រែក (ភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប) ឱ្យបាន និងបញ្ចប់នៅចុងឆ្នាំ២០១០។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC), សម្ព័ន្ធការពារធនធានធម្មជាតិ (FACT), សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកដំណាក់ចង្អើរ និងក្រុងកែបនៅក្នុងខេត្តកែប។

សិក្ខាសាលាម្ចាស់ឆ្នោតនេះជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាច ឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*


- លោក **គីម ឈន** អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៩
- លោក **សុខ ពិនុរ្យ** អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦